អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

* * *

## អនុក្រឹត្យ លេខ ៥០ អនក្រ.បក

## ស្តីពី

## ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមស្ថានភាពវិវត្តន៍និងចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា

**សំរេច**

មាត្រា ១._ត្រូវបានបង្កើតគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស ។ គណៈកម្មការនេះ មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

មាត្រា ២._គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស មានបេសកកម្មប្រតិបត្តិឃ្លាំមើល និង ដោះស្រាយការងារសិទ្ធិមនុស្សជាអចិន្ត្រៃយ៍ ។

មាត្រា ៣._គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស រួមមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១_លោក **ឆន សារាយ** | ប្រធានអង្គការអាត់ហុក | ប្រធាន |
| ២_លោកស្រី **ពុង ឈីវកេច** | ប្រធានអង្គការលីកាដូ | សមាជិក |
| ៣_លោក **ខាវ ចំរើន** | ប្រធានគណៈកម្មាធិការសំរបសំរួលកម្ពុជា | សមាជិក |
| ៤_ទីប្រឹក្សានាយករដ្ឋមន្ត្រីទី១ | | សមាជិក |
| ៥_ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ | | សមាជិក |

សមាសភាពគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្សនេះ មានលាភការស្មើរដ្ឋមន្ត្រីទាំងប្រធាន និងសមាជិកទាំងអស់ ។

មាត្រា ៤._ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់គណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស ត្រូវកំណត់ដោយអនុក្រឹត្យមួយផ្សេងទៀត ។

មាត្រា ៥._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ និងអស់លោក លោកស្រី ដែលមាននាមចែងក្នុងមាត្រា ៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

* * *